ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ០៤

ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៤

សាលដីកា

លេខ : ៤៣

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ប្រាក់ គីមសាន ចៅក្រម

៤- លោក ស៊ិន ឌីម ចៅក្រម

៥- លោក ប៉ែន សារឿន ចៅក្រម-របាយការណ៍

ក្រឡាបញ្ជី

លោក សាន សុជាត

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១២"ឃ" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ០៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ចំពោទ*** : បង្ករបួសស្នាមបណ្តាលឱ្យរលូតកូន ប្រព្រឹត្តិនៅភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៤១ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

១-ជនជាប់ចោទឈ្មោះហៃ ចាន់នី (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើចំការ ទីលំនៅសព្វថ្ងៃភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ឪពុកឈ្មោះ យី ក្រោ "វ" ម្តាយឈ្មោះគ្រុយ បារស៊ឹម នៅលីវ ។ ក្រៅឃុំ ។

២-ជនជាប់ចោទឈ្មោះគ្រុយ ប៉ារស៊ឹម ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើចំការ ទីលំនៅសព្វថ្ងៃភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ។

៣-ជនជាប់ចោទឈ្មោះហៃ ចាន់ណា ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើចំការ ទីលំនៅសព្វថ្ងៃភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ។

៤-ជនជាប់ចោទឈ្មោះ ហៃ សុខចាន់ ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើចំការ ទីលំនៅសព្វថ្ងៃភូមិសំបាំនលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល ។

-ជនរងគ្រោះឈ្មោះស្រ៊ុន ចាន់ធី (ជាចុងបណ្ដឹងសាទុក្ខ) ភេទស្រី អាយុ៣៦ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើចំការ ទីលំនៅសព្វថ្ងៃភូមិសំបាំនលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល ។

-តាមពាក្យបណ្ដឹង ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩៩ និង ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៩ ខ្លួនសុំប្ដឹងពីឈ្មោះគ្រុយ ប៉ាវស៊ឹម .ហៃ ចាន់ណា . ហៃ ចាន់នី .ហៃ សុខចាន់ .ហៃ ឃ្លាង និង ឈ្មោះជន រុំ ពីបទបង្ករបួសស្នាមព្រួតគ្នាវាយមកលើខ្លួនបណ្ដាលឱ្យរលូតកូន ។ ខ្លួនប្ដឹងសុំទាមទារជំងឺចិត្ត និង ថ្លៃថ្នាំព្យាបាលសរុបចំនួន៣.៥០០.០០០រៀល ហើយសូមផ្ដន្ទាទោសជនល្មើសតាមច្បាប់ ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តកណ្ដាល ថា : សំរេចចោទប្រកាន់លើឈ្មោះគ្រុយ ប៉ាវស៊ឹម .ហៃ ចាន់នី .ហៃ ចាន់ណា និង ហៃ សុខចាន់ ពីបទបង្ករបួសស្នាមបណ្ដាលឱ្យរលូតកូនដោយចេតនា ប្រព្រឹត្តិនៅភូមិសំបាំនលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៩ តាមមាត្រា៤១ ច្បាប់ព្រហ្មទណ្ឌអន្តរកាលប្រាកដមែន ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២១"ក" ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ របស់តុលាការខេត្តកណ្ដាល ដែលបានសំរេច :

១-ផ្ដន្ទាទោស :

ក/-ឈ្មោះ គ្រុយ ប៉ាវស៊ឹម ដាក់ពន្ធនាគារកំណត់៦ខែ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង០៥ឆ្នាំ តាមកំណត់ច្បាប់ ។

ខ/-ឈ្មោះ ហៃ ចាន់នី ដាក់ពន្ធនាគារកំណត់៨ខែ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង០៥ឆ្នាំ តាមកំណត់ច្បាប់ ។

គ/-ឈ្មោះ ហៃ ចាន់ណា ដាក់ពន្ធនាគារកំណត់៦ខែ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង០៥ឆ្នាំ តាមកំណត់ច្បាប់ ។

ឃ/-ឈ្មោះ ហៃ សុខចាន់ ដាក់ពន្ធនាគារកំណត់៦ខែ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង០៥ឆ្នាំ តាមកំណត់ច្បាប់ ។

ពីបទ : បង្ករបួសស្នាមបណ្ដាលឱ្យរលូតកូន ប្រព្រឹត្តិនៅភូមិសំបាំនលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៩ តាមមាត្រា៤១ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់ឱ្យគ្រុយ ប៉ាវស៊ឹម .ហៃ សុខចាន់ .ហៃ ចាន់ណា និង ហៃ ចាន់នី សងជំងឺចិត្ត និង ថ្លៃថ្នាំព្យាបាលចំនួន២លានរៀល សំណើលើសពីនេះលើកចោល ។ ក្នុងករណីគ្មានប្រាក់សងទេ ត្រូវដាក់គុកបង្ខំរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ ។

៣-សាលក្រមនេះ ជំនុំជំរះជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះគ្រុយ ប៉ាវស៊ីម ហៃ ចាន់នី និង ជនរងគ្រោះឈ្មោះស្រ៊ុន ចាន់នី កំបាំងមុខជនជាប់ចោទឈ្មោះហៃ ចាន់ណា និង ហៃ សុខចាន់ ។ សំរេចបើកផ្លូវប្តឹងទាស់នឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣១ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០របស់ឈ្មោះគ្រុយ ប៉ាវស៊ីម ហៃ សុខចាន់ ,ហៃ ចាន់នី និង ហៃ ចាន់ណា ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ២១"ក" ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ របស់តុលាការខេត្តកណ្តាល លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : សុំបដិសេធសាលក្រមតុលាការខេត្តកណ្តាល ឈ្មោះគ្រុយ ប៉ាវស៊ីម ,ហៃ ចាន់ណា ,ហៃ សុខចាន់ ឱ្យរួចខ្លួនពីបទចោទ និង ឈ្មោះហៃ ចាន់នី ត្រូវចោទពីបទ បង្ករបួសស្នាមប្រាកដមែន ។

-បានឃើញសាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ១៤"ឃ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២១"ក" ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ របស់តុលាការខេត្តកណ្តាលទុកជាបានការ ។

៣-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់លេខ០៩ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះគ្រុយ ប៉ាវស៊ីម , ហៃ ចាន់នី ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១៤ "ឃ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១២"ឃ" ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងទាស់របស់ឈ្មោះគ្រុយ ប៉ាវស៊ីម , ហៃ ចាន់នី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាកំបាំងមុខលេខ១៤"ឃ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខឈ្មោះគ្រុយ ប៉ាវស៊ីម និង ហៃ ចាន់នី ជាលើកទីII ចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៦២ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះ ហៃ ចាន់នី ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១២"ឃ" ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៤ របស់ឈ្មោះហៃ ចាន់នី ( ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប របស់ឈ្មោះស្រ៊ុន ចាន់ធី ( ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះហៃ ចាន់នី , គ្រុយ ប៉ាវស៊ីម , ហៃ ចាន់ណា និង ហៃ សុខចាន់ ពីបទបង្ករបួសស្នាមបណ្តាលឱ្យរលូតកូនប្រាកដមែន ។ ដូច្នេះសូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះហៃ ចាន់នី ( ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : មូលហេតុដែលនាងខ្ញុំប្តឹងសាទុក្ខពីសាលដីកាសាលាឧទ្ធរណ៍ មកពីឈ្មោះស្រ៊ុន ចាន់ធី ក្រោយពីមានការវាយគ្នាបាន៣-៤ថ្ងៃ រួចហើយ១ ទើបថាខ្លួនរលូតកូន នាងខ្ញុំមិនទទួលស្គាល់សំបុត្រពេទ្យនេះទេ ព្រោះនាងខ្ញុំមិនបានវាយលើ ស្រ៊ុន ចាន់ធី ទេ ការវាយគ្នានេះគ្រាន់តែបោចសក់គ្នាទៅវិញទៅមក ។ ដូច្នេះសូមតុលាការជួយរកយុត្តិធម៌ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះស្រ៊ុន ចាន់ធី ( ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : អំបាញ់មិញនាងខ្ញុំបានស្តាប់ការលើកឡើងរបស់ ហៃ ចាន់នី ហើយ នាងខ្ញុំសូមបដិសេធចោល ព្រោះ ហៃ ចាន់នី និយាយគ្មានការពិតទេ នាងខ្ញុំបានទៅហៅប្អូនរបស់នាងខ្ញុំមកផ្ទះវិញ ខ្ញុំទាញប្អូននាងខ្ញុំមកផ្ទះស្រាប់តែជនជាប់ចោទមកវាយនាងខ្ញុំតែម្តង ។ ក្រោយពីវាយគ្នាហើយ នាងខ្ញុំចុកពោះឈឺចុងដង្ហើមហើយទៅពិនិត្យពេទ្យ ទើបនាងខ្ញុំដឹងថា នាងខ្ញុំរលូតកូន ។ នាងខ្ញុំសំណូមពរ សូមប្តឹងទាមទារជំងឺចិត្ត ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : តាមចម្លើយរបស់ជនជាប់ចោទជនរងគ្រោះ និងតាមចំលើយសាក្សីក្នុងសុំណុំរឿង មានភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទប្រាកដមែន ។ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ឈ្មោះហៃ ចាន់នី និង ឈ្មោះស្រ៊ុន ចាន់ធី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៦២ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះ ហៃ ចាន់នី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការលើកឡើងរបស់ឈ្មោះហៃ ចាន់នី ក្នុងសារណា ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៤ ក៏ដូចចំលើយនាពេលសវនាការនេះដែរ ថា : តុលាការថ្នាក់ក្រោមសំរេចសេចក្តីពុំយុត្តិធម៌ជឿតែភាគីម្ខាង ការលើកឡើងនោះជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

+ចំលើយសាក្សីឈ្មោះហៀង សារ៉ាត់ និង ហុក ហេង បានបំភ្លឺច្បាស់លាស់ថា ពិតជាបានឃើញគ្រួសារ គ្រុយ ប៉ាវស៊ីម ចំនួន៤-៥នាក់ បានដេរបញ្ចោរគ្នា រហូតដល់ប្រវាយប្រតប់គ្នាទៅវិញទៅមក និង ឈ្មោះហៃ ចាន់នី បានលុតជង្គង់ពីលើពោះជនរងគ្រោះ ហើយបោចសក់ថែមទៀតផង ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១២"ឃ" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី

១-ទទួលបណ្តឹងសាទុក្ខលេខ៦២ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះហៃ ចាន់នី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១២"ឃ" ចុះថ្ងៃទី៣១ខែមករាឆ្នាំ២០០៣របស់សលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤ ។